**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៤៩...អនក្រ..បក

*អនុក្រឹត្យ*

**ស្តីពី**

**ការប្រើប្រាស់គណនី**

**ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ**

៚ ✧ ៚

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៣
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាលចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** : អនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រើប្រាស់គណនី " ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ " ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ លើមុខសញ្ញាចំណាយសំរាប់ចូលរួមជាបដិភាគជាមួយវិភាគទានរបស់ប្រជាពលរដ្ឋតាមរូបភាពរដ្ឋ ៥០% ប្រជាពលរដ្ឋ ៥០% ក្នុងការស្ថាបនាក្រាលកៅស៊ូផ្លូវក្នុងរាជធានីភ្នំពេញ ដែលមានទឹកប្រាក់សរុបចំនួន ១.៣០៨.៣០០ដុល្លារអាមេរិក ។ ចំពោះទឹកប្រាក់ដែលត្រូវចំណាយពិតប្រាកដ នឹងកំណត់ច្បាស់លាស់ ក្រោយពីធ្វើបែបបទលទ្ធកម្មសាធារណៈរួច ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៤

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**